២-លោក ម៉ក់ គឹមហុង ប្រធានអគ្គនាយកចំការកៅស៊ូជុប

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

***

## ២.- សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០០១

**សេចក្តីសំរេច លេខ ២២ សសរ**

**ស្តីពី**

**ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព**

**ឯកឧត្តម ឡៅ មែន សមាជិកឧត្តមក្រុមប្រឹក្សាយោធាព្រះមហាក្សត្រ**

~~~

-យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

-យោងតាមសំណូមពរ និងការចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការចំរុះមួយ ដើម្បីរៀបចំបុណ្យសព ឯកឧត្តម **ឡៅ មែន** ដែលមានសមាសភាពដូចខាងក្រោមៈ

| | | |
|---|---|---|
| ១-ឯកឧត្តម | **ទៀ បាញ់** | ប្រធាន |
| ២-ឯកឧត្តម | **អ៊ឹ សារាវុធ** | អនុប្រធាន |
| ៣-ឧត្តមសេនីយ៍ឯក | **នាង ផាត** | អនុប្រធាន |
| ៤-ឧត្តមសេនីយ៍ឯក | **សូ ផន** | អនុប្រធាន |
| ៥-ឧត្តមសេនីយ៍ឯក | **សៅ សុខា** | អនុប្រធាន |

www.pheakdeylaw.com
~~~

| | | |
|---|---|---|
| ៦-ឯកឧត្តម | ជា សុខុម | សមាជិក |
| ៧-ឯកឧត្តម | ជា តាន | សមាជិក |
| ៨-ឯកឧត្តម | ញ៉ែម ម៉ាលី | សមាជិក |
| ៩-ឯកឧត្តម | ម៉ម់ សារិន | សមាជិក |
| ១០-ឯកឧត្តម | ឥត សារ៉ាត់ | សមាជិក |
| ១១-ឯកឧត្តម | ហង្ស សុត | សមាជិក |
| ១២-លោក | ហ៊ុល ផានី | សមាជិក |
| ១៣-លោក | ប្អូន លីមហេង | សមាជិក |
| ១៤-លោក | ខូយ គីមឆ្ល | សមាជិក |
| ១៥-លោក | ស្វ សីហា | សមាជិក |
| ១៦-លោក | ផេង តិរុណា | សមាជិក |
| ១៧-លោក | គីម សុផាណា | សមាជិក |
| ១៨-លោក | សៅ ចាន់តារា | សមាជិក |
| ១៩-លោក | ទូច ទិចិត្រ | សមាជិក |

**ប្រការ ២** គណៈកម្មការនេះមានភារកិច្ច :

-ទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម ទៀប បែន សមាជិក ប្រឹក្សាយោធាព្រះមហាក្សត្រ ឱ្យបានល្អប្រសើរ ស្របតាមប្រពៃណីជាតិ ប្រពៃណីសាសនា និងឱ្យបានសក្តិសមនឹងកិត្តិយសរបស់សព ។

-រៀបចំកម្មវិធីលំអិត សំរាប់បុណ្យសព ពិធីការ ទទួលភ្ញៀវជាតិ អន្តរជាតិ ដែលត្រូវអញ្ជើញគោរពវិញ្ញាណក្ខន្ធសព រៀបចំវិយោគកថា និងឯកសារផ្សេងៗដែលចាំបាច់ ។

-រៀបចំពិធីបុណ្យបូជាសពតាមប្រពៃណីសាសនា និងប្រពៃណីជាតិ ដោយសហការជិតស្និទ្ធជាមួយគ្រួសារសព ។

-ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។

-រៀបចំក្បួនដង្ហែសព ពិធីដង្ហែសព និងពិធីបូជាសពឱ្យបានល្អប្រសើរ ។

-គណៈកម្មការនេះអាចបង្កើតអនុគណៈកម្មការជំនាញមួយចំនួនទៀត តាមតម្រូវការចាំបាច់ដើម្បីជាជំនួយការ ។

www.pheakdeylaw.com

-គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ -អន្តរជាតិ ។

-សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ អភិបាលរាជធានីភ្នំពេញ ប្រធានគណៈកម្មការរៀបចំបុណ្យសពឯកឧត្តម ទៀប បែន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសមាសភាពគណៈកម្មការ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

≈≈≈

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០១

## សេចក្តីសំរេច លេខ ២៣ សសរ

## ស្តីពី

## ការបង្កើតក្រុមការងារសំរបសំរួលជាមួយ

## សមាគមន៍អ្នកផ្តល់ជំនួយ

~~~

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ សង្កាត់

www.pheakdeylaw.com
~~~